# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ៧៧០៥ កសក

រាជធានីភ្នំពេញ, ថ្ងៃទី.១២...ខែ.កញ្ញា..ឆ្នាំ២០១៦

## ជម្រាបជូន
## លោកប្រធានមន្ទីរកសិកម្មរាជធានី-ខេត្ត

**កម្មវត្ថុ** ៖ សំណើចាត់វិធានការទប់ស្កាត់ការប្រមូលទិញកសិផលដោយបន្ទាបថ្លៃពីសំណាក់ឈ្មួញ និងក្រុមហ៊ុនធ្វើអាជីវកម្ម ផលិតផលកសិកម្ម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាប លោកប្រធានមន្ទីរកសិកម្មរាជធានី ខេត្ត ជ្រាបថា ការងារបង្កបង្កើនផលកសិកម្មកំពុងមមាញឹក និងជិតចប់សព្វគ្រប់ហើយ ទន្ទឹមនឹងនេះកសិករមួយចំនួនបាននិងកំពុងធ្វើការប្រមូលផលជាបន្តបន្ទាប់ដែលមកទល់ពេលនេះការប្រមូលផលស្រូវស្រាលសម្រេចបានចំនួន ១២០ ៧៣៤ហ.ត លើផ្ទៃដីអនុវត្តស្រូវស្រាលសរុប ៥៩១ ៥១៤ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ៤៧៣ ០៣៥តោន លើសឆ្នាំមុន ២៣ ៥៧៩តោន។ ដូចនេះ ដើម្បីរក្សាស្ថិរភាពថ្លៃកសិផល ពិសេសថ្លៃស្រូវដែលតែងតែកើតឡើងក្រោយពេលប្រមូលផលដោយសារឈ្មួញប្រមូលទិញបន្ទាបថ្លៃធ្វើឱ្យមានការត្អូញត្អែរពីប្រជាកសិករនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្នើលោកប្រធានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធចាត់វិធានការដូចខាងក្រោម៖

- ទប់ស្កាត់នូវការប្រមូលទិញផ្តាច់មុខពីសំណាក់ឈ្មួញនៅតាមតំបន់ ដើម្បីធ្វើការចរចាថ្លៃឱ្យបានសមស្របតាមស្ថានភាពថ្លៃជាក់ស្តែង និងលើកជាវិធានការជូនរដ្ឋបាលរាជធានី ខេត្តដើម្បីចូលរួមដោះស្រាយ
- ពង្រឹងសមត្ថភាពសហគមន៍កសិកម្មមូលដ្ឋានលើការប្រមូលទិញកសិផល ពិសេសសន្និធិស្រូវដើម្បីចរចាថ្លៃជាមួយវិស័យឯកជន
- ធ្វើការចរចាជាមួយសមាគមម៉ាស៊ីនកិនស្រូវប្រចាំខេត្ត ដើម្បីប្រមូលទិញស្រូវពីប្រជាកសិករឱ្យអស់លទ្ធភាពក្នុងតម្លៃសមស្រប។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកប្រធាន ជ្រាប និងអនុវត្តតាមខ្លឹមសារខាងលើឱ្យមានប្រសិទ្ធភាពតាមការគួរ។

សូម លោកប្រធានមន្ទីរកសិកម្មរាជធានី ខេត្ត ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- សាលារាជធានី-ខេត្ត
  "ដើម្បីសហការ"
- គ្រប់អង្គភាពក្រោមឱវាទក្រសួង
  "ដើម្បីមុខការ"
- ឯកសារ កាលប្បវត្តិ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320